# ដូរ!

ដោយ ខូ តាភបុត្តិ ថ្ងៃទី៧ កក្កដា ២០១៣










១. គ្រប់ទីកន្លែងថ្លែងទុក្ខា ថ្លែងទុក្ខខ្លោចផ្សាកំពុងមាន
ទុក្ខគេរឹបផ្ទះទាំងបំពាន ទុក្ខគេទន្ទ្រានគ្មានឡើយច្បាប់។

២. ទាមទារតវ៉ាសារជាថ្មី ចង់បានត្រឹមដីវ៉ាយវ៉ាប់ប្រាប់
អង្វរគ្រប់ពាក្យគ្មានអ្នកស្តាប់ ថែមទាំងចងចាប់ដាក់ទោសទណ្ឌ។

៣. រដូវបោះឆ្នោតបានមកដល់ មិនចោលកិច្ចកលប្តូលរង្វាន់
ចង់បានសន្លឹកឆ្នោតគ្រប់គ្រាន់ បន្តជិះជាន់រាស្ត្រប្រជា។

៤. ដៃគេសំពះឪនលន់តួ រៀបឫកយកគួរគ្រប់ៗគ្នា
ដីផ្ទះដែលបាត់គេផ្តន្ទា បណ្តោញគ្រប់គ្រាចំណាំច្បាស់។

៥. សម្តីថ្ងៃមុនមហាឃោរឃៅ វ៉ៃទៅបាញ់ទៅទោះក្មេងចាស់
ថ្ងៃនេះរាបសាហាក្រឡាស់ សមសួនខ្លាំងណាស់ស្គាល់ចាស់ទុំ។

៦. យើងចាំមិនភ្លេចម្តងណាសោះ នៅរំស្រស់ៗគ្រាជួបជុំ
ដីឯងផ្ទះឯង គេចាប់ឃុំ កូនៗទួញយំអាណិតម៉ែ។

៧. ម្តងនេះសម្រេចត្រូវតែដូរ ចៀសទឹកភ្នែកហូរ ហូរឥតល្ហែ
ប្តូរហើយសង្គ្រោះទាំងជាតិខ្មែរ អនាគតប្រែកែសង្គម៕